ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# លិខិតបទដ្ឋានគតិយុត្តិសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងដីសម្បទានសេដ្ឋកិច្ច

| ល.រ | លេខលិខិត | ថ្ងៃខែលិខិត | របស់ | កម្មវត្ថុ |
|---|---|---|---|---|
| ១ | ១៤៦ អនក្រ.បក | ២៧-ធ្នូ-២០០៥ | រាជរដ្ឋាភិបាលកម្ពុជា | អនុក្រឹត្យ ស្ដីពី សម្បទានដីសេដ្ឋកិច្ច |
| ២ | ៦៩ អនក្រ.បក | ២៨-មេសា-២០១៦ | រាជរដ្ឋាភិបាលកម្ពុជា | អនុក្រឹត្យ ស្ដីពី<br>ការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្តល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន |
| ៣ | ៩០ សសរ | ២៦-វិច្ឆិកា-២០១៨ | រាជរដ្ឋាភិបាលកម្ពុជា | សេចក្ដីសម្រេច ស្ដីពី<br>ការតែងតាំងសមាសភាព នៃលេខាធិការដ្ឋានបច្ចេកទេស សម្រាប់សម្បទានដីសេដ្ឋកិច្ច |
| ៤ | ១១៣០ សជណ | ០១-តុលា-២០១២ | ទីស្ដីការគណៈរដ្ឋមន្ត្រី | ករណីកែសម្រួលការកំណត់ថ្លៃសម្បទានដី និងបង់ប្រាក់កក់ ចំពោះសម្បទានដីសេដ្ឋកិច្ចទាំងអស់ (ទាំងចាស់ ទាំងថ្មី) |
| ៥ | ៨១១ សជណ.ហធ | ១២-មិថុនា-២០១៩ | ទីស្ដីការគណៈរដ្ឋមន្ត្រី | ករណីសំណើសុំគោលការណ៍លើការផ្ទេរធនធានចំណូលមិនមែនសារពើពន្ធ ពីចំណូលថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ |

| | | | | |
|---|---|---|---|---|
| ៦ | ១២៧៦ សហវ. ប្រក | ២៥-ធ្នូ-២០០៩ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រកាស ស្តីពី<br>ការកំណត់ថ្លៃសួយសារឈើឈរឡើងវិញ ដើម្បីបង់ចំណូលថវិការដ្ឋ |
| ៧ | ៧១៥/៥៨៥ ប្រក. សហវ.កសក | ២៣-កញ្ញា-២០១០ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រកាសរួម ស្តីពី<br>ការកែសម្រួលប្រការ២ នៃប្រកាសលេខ ១២៧៦ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកំណត់ថ្លៃសួយសារឈើឈរឡើងវិញ ដើម្បីបង់ចំណូលថវិការដ្ឋ |
| ៨ | ៣៦៩ ប្រក.កសក | ២១-មិថុនា-២០១៦ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រកាស ស្តីពី<br>ការបង្កើតក្រុមជំនួយការលេខាធិការដ្ឋានបច្ចេកទេសសម្បទានដីសេដ្ឋកិច្ច |
| ៩ | ៦២១ ប្រក.កសក | ១៤-វិច្ឆិកា-២០១៧ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រកាស ស្តីពី<br>ការកែសម្រួលប្រធានក្រុមជំនួយការលេខាធិការដ្ឋានបច្ចេកទេស សម្រាប់សម្បទានដីសេដ្ឋកិច្ច |
| ១០ | ៥៩០៣/៣៨២ កសក.នផ.ផក | ០៥-កញ្ញា-២០១៣ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សេចក្តីណែនាំលើការអនុវត្តនិងការផ្តល់របាយការណ៍ស្តីពី លទ្ធផលនៃការអនុវត្តគម្រោងវិនិយោគដីសម្បទានសេដ្ឋកិច្ច |
| ១១ | ៦៩១ សណន. កសក | ២៥-វិច្ឆិកា-២០១៦ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សេចក្តីណែនាំ ស្តីពី<br>វិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច |
| ១២ | ៧៥១៤ កសក | ២៣-សីហា-២០១៧ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សំណើរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ឱ្យបានរួចរាល់តាមនីតិវិធី |

| | | | | |
|---|---|---|---|---|
| ១៣ | ១០៧៧៣ កសក | ១១-ធ្នូ-២០១៧ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | លិខិតជូនដំណឹង ស្តីពី<br>ការជំរុញការអនុវត្តកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនរដ្ឋ |
| ១៤ | ២០០២ កសក | ២៨-កុម្ភៈ-២០១៩ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ស្តីពីការពង្រឹងការអនុវត្តគម្រោងសម្បទានដីសេដ្ឋកិច្ច |
| ១៥ | ១២០៩១ កសក | ២២-វិច្ឆិកា-២០១៩ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ស្តីពីការយកចិត្តទុកដាក់ពង្រឹងការចុះបញ្ជីដីរដ្ឋក្នុងដែនសមត្ថកិច្ច<br>របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត |
| ១៦ | ១៣៣០៤/១៩៣៥<br>កសក.គហ | ២៥-ធ្នូ-២០១៩ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ស្តីពីការកំណត់លើការគណនាថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ចត្រូវបង់ចូលថវិការដ្ឋ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៤៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## សម្បទានដីសេដ្ឋកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/0៧0៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២00៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ 0២/នស/៩៤ ចុះថ្ងៃទី២0 ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ0៤/នស/៩៤ ចុះថ្ងៃទី១0 ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦ ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/0២៩៨/0៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង
- បានឃើញព្រះរាជក្រមលេខ នស/រកម/0៣0១/0៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២00១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/0៨0១/១៤ ចុះថ្ងៃទី៣0 ខែសីហា ឆ្នាំ២00១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លី ដែលមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីនីតិវិធី ការបង្កើតការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៥ ។

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ ..**

អនុក្រឹត្យនេះមានគោលដៅកំណត់លក្ខណៈវិនិច្ឆ័យ នីតិវិធី យន្តការ និងការរៀបចំស្ថាប័ន សម្រាប់ការផ្តួចផ្តើម និងការផ្តល់សម្បទានដីសេដ្ឋកិច្ច សម្រាប់ការតាមដានត្រួតពិនិត្យការអនុវត្តកិច្ចសន្យា និងសម្រាប់ការត្រួតពិនិត្យឡើងវិញលើសម្បទានដីសេដ្ឋកិច្ចដែលបានចុះកិច្ចសន្យាមុនពេលដែលអនុក្រឹត្យនេះចូលជាធរមាន ស្របតាមការកំណត់នៃច្បាប់ភូមិបាលឆ្នាំ ២០០១។

**មាត្រា ២ ..**

ពាក្យទាំងឡាយខាងក្រោមនេះ មានន័យដូចតទៅ÷

- សម្បទានដីសេដ្ឋកិច្ច សំដៅដល់យន្តការសម្រាប់ផ្តល់ដីឯកជនរបស់រដ្ឋ តាមរយៈកិច្ចសន្យាសម្បទានមួយជាក់លាក់ទៅឱ្យសម្បទានិក ដើម្បីប្រើប្រាស់សម្រាប់ធ្វើអាជីវកម្មកសិកម្ម និងកសិ-ឧស្សាហកម្ម
- ការធ្វើអាជីវកម្មកសិ-ឧស្សាហកម្ម សំដៅដល់
    - ការដាំដំណាំស្បៀង ឬ ដំណាំឧស្សាហកម្ម រាប់ទាំងការដាំដើមឈើជាចំការឈើ
    - ការចិញ្ចឹមសត្វ និងវារីវប្បកម្ម
    - ការងារសាងសង់ ដូចជារោងសិប្បកម្ម ឬរោងចក្រ និងការបំពាក់បរិក្ខារនានាសម្រាប់កែច្នៃ